លេខៈ០៩សសក                                                    រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែកញ្ញា

# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !**

អស់រយៈពេលជិត២ខែហើយ ដែលកងទ័ពថៃមិនព្រមបោះបង់មហិច្ឆតាឈ្លានពានចង់បានទឹកដីខ្មែរ ដោយមិនព្រមដកទព័ថយចេញពីទឹកដីខ្មែរ បន្ទាប់ពីកងកម្លាំងយោធាថៃទាំងនោះ បានចូលមកឈ្លានពានទឹកដីខ្មែរ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ នៅតាមបណ្តោយព្រំដែនកម្ពុជា-សៀម ជាពិសេសនៅភូមិសាស្រ្តខេត្តព្រះវិហារ (វត្តកែវសិក្ខាគីរីស្វារៈ) និង ភូមិ សាស្រ្តខេត្តឧត្តរមានជ័យ (ប្រាសាទតាមាន់ធំ និង ប្រាសាទតាមាន់តូច) ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ឱកាសបើកការចចារតាមផ្លូវការទូតរវាងប្រទេសទាំងពីរ ក្នុងន័យរក្សាចំណងមិត្តភាព សន្តិភាព ជាប្រទេសជិតខាងគ្នា ម្តងជាពីរដងរួចហើយក៏ដោយ ក៏រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏ មិនបានបញ្ជាឱ្យកងកម្លាំងយោធារបស់ខ្លួន ដកចេញពីទឹកដីខ្មែរនោះទេ ហើយថែមទាំងឈ្លានពាន ជាបន្តបន្ទាប់ និង ប្រមាថធ្វើបាប ថែមទាំងបាញ់ប្រហារមកលើប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមព្រំដែនជាបន្តបន្ទាប់ ។

បញ្ហាកងទព័សៀមឈ្លានពានទឹកដីខ្មែរ កាន់តែធ្ងន់ធ្ងរទៅៗ ពីមួយថ្ងៃ ទៅមួយថ្ងៃ ហើយក្នុងនាមជាប្រជាពលរដ្ឋខ្មែរ មានការកង្វល់យ៉ាងខ្លាំង ចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលមានជំហរមិនច្បាស់លាស់ ធ្វើឱ្យពេលវេលាចេះតែអូសបន្លាយ ដែលអាចធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី ។ ដើម្បីធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីខ្មែរ ទូលព្រះបង្គំ សូមព្រះអង្គប្រើព្រះរាជសិទ្ធិរបស់ព្រះអង្គ ដែលយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា **ជំពូកទី២** ត្រង់ **មាត្រា៨** បានចែងថាៈ

ព្រះមហាក្សត្រព្រះអង្គ ទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។

ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និង ការគោរពសន្ធិសញ្ញាអន្តរជាតិ ។

អាស្រ័យដូចបានទូលថ្វាយខាងលើ ទូលព្រះបង្គំខ្ញុំ សង្ឃឹមថា ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងទ្រង់ នឹង

ប្រើព្រះរាជសិទ្ធិរបស់ព្រះអង្គដោះស្រាយអំពីកងទព័សៀមឈ្លានពានចង់បានទឹកដីខ្មែរ ជាក់ជាមិនខាន ។

សូមព្រះករុណាជាអម្ចាស់ជីវិតម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពបរិបូរណ៍ ព្រះកាយពលមាំមួន ដើម្បីជាម្លប់ដល់ប្រជារាស្ត្រខ្មែរគ្រប់រូប ។

គួរពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងទ្រង់ព្រះរាជទានទោសដល់ទូលព្រះបង្គំ ។

**ប្រធាន**

**[ហត្ថលេខា]**

ចម្លងជូនៈ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស

-ស្ថានទូតនានាប្រចាំនៅកម្ពុជា

-អង្គការនានាប្រចាំកម្ពុជា

-ឯកសារ-កាលប្បវត្តិ